# កិច្ចព្រមព្រៀង

ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០ នៅក្រុមហ៊ុន.ស៊ីនចាង ថេក អ៊ីន បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព អ្នកស្រី Jin Aiying ជាតំណាងក្រុមហ៊ុន ស្ដីពីការព្យួរ កិច្ចសន្យាការងារមួយរយៈដោយមូលហេតុមិនមានការបញ្ជាទិញតទៅទៀត ធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបានពេញលេញក្នុងរយៈពេល០១ខែ ។

សមាសភាពចូលរួមៈ

1- ភាគីតំណាងរោងចក្រ

- លោកស្រី Jin Aiying. តំណាងនាយករោងចក្រ
- កញ្ញា សំរិត វណ្ណារី.ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោក ហែម ផល្លី
- លោក ម៉ាក់ វណ្ណៈ

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន..១៤....នាក់ ក្នុងចំណោមកម្មករសរុបចំនួន ៣៨ ក្នុងរយៈពេល១ខែ ដោយគិតចាប់ពីថ្ងៃទី..១៦ ខែ.កក្កដា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី.១៥ ខែ.សីហា ឆ្នាំ ២០២០។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្ដល់ទៅតាមសេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាលស្ដីពីការផ្ដល់ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យានេះ ។

3- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៦:០០នាទី នាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃ.ពុធ ០៣រោច ខែអាសាឍ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ.កក្កដា ឆ្នាំ២០២០

បានឃើញនឹងឯកភាព

តំណាងនាយកក្រុមហ៊ុន

បានឃើញនឹងឯកភាព

តំណាងកម្មករ